# កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋានរបស់រដ្ឋាភិបាលផ្តល់ក្តីសង្ឃឹមដល់គ្រួសារគ្មានដី និងខ្វះដីនៅឃុំប្រស្នឹប



អ្នកស្រី ស៊ុន កែវ កំពុងកាត់ឧសជាកំណាត់ នៅចំហៀងផ្ទះខ្ទមរបស់ម្តាយគាត់។



អ្នកស្រី ស៊ុន កែវ ស្ថិតក្នុងចំណោមគ្រួសារក្រីក្រគ្មានដីនិងខ្វះដីចំនួន ២០៧គ្រួសារ ដែលបានដាក់ពាក្យស្នើសុំទាំងដីលំនៅឋាន និងទាំងដីកសិកម្ម ពីគម្រោងឡាសិត ៣ ដែលកំពុងអនុវត្តដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ដនស) និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅក្នុងខេត្តគោលដៅចំនួន ១២ ក្នុងប្រទេសកម្ពុជា។

នៅខែមិថុនា ឆ្នាំ២០២៣ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យកាត់ឆ្វៀលដីទំហំ ៣២២ ហិកតា ស្ថិតក្នុងឃុំប្រស្នឹប ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ធ្វើអនុបយោគពីដីសាធារណរបស់រដ្ឋទៅជាដីឯកជនរបស់រដ្ឋ តាមសំណើរបស់ក្រសួងដនស សម្រាប់អនុវត្តគម្រោងឡាសិត ៣។ យោងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោង អ្នកដាក់ពាក្យស្នើសុំដីនីមួយៗ នឹងទទួលបានដីលំនៅឋានចំនួនមួយឡូត៍ទំហំ ៣០ម x ៤០ម និងដីកសិកម្មចំនួនមួយឡូត៍ទំហំមួយហិកតា។

អ្នកស្រី កែវ អាយុ ៣៦ឆ្នាំ បានបង្ហាញនូវក្តីរីករាយ បន្ទាប់ពីទទួលបានលិខិតអញ្ជើញពីលោកមេភូមិ ឱ្យទៅចូលរួមប្រជុំស្តាប់ការផ្សព្វផ្សាយអំពីគម្រោង នៅវត្តប្រស្នឹប ស្ថិតក្នុងឃុំប្រស្នឹប នៅខែមិថុនា ឆ្នាំ២០២៣។

ដោយសារតែប្តីរបស់គាត់តែងតែវាយធ្វើបាបគាត់ជាញឹកញាប់ អ្នកស្រី កែវ បានសម្រេចចិត្តលែងលះជាមួយប្តី ហើយរស់នៅជាមួយកូនតូចៗទាំង៥នាក់របស់គាត់ ដែលកូនពៅមានអាយុ៤ខែ ឯកូនច្បងអាយុ១៤ឆ្នាំ។ បច្ចុប្បន្ន អ្នកស្រី កែវ គ្មានផ្ទះផ្ទាល់ខ្លួនទេ។ គាត់និងកូនៗ រស់នៅជាមួយម្តាយចាស់ ក្នុងផ្ទះតូចទ្រុឌទ្រោមមួយ ស្ថិតនៅភូមិត្រពាំង អំពិល ឃុំប្រស្នឹប។

គ្រួសារអ្នកស្រីកែវមានជីវភាពលំបាកជាងគេនៅក្នុងភូមិ។ គាត់រកស៊ីលក់ឧសដើម្បីចិញ្ចឹមជីវិត។ រៀងរាល់ពីរសប្តាហ៍ម្តង គាត់និងកូនប្រុសច្បងធ្វើដំណើរដោយថ្មើរជើងទៅកាប់កូនឈើតូចៗនៅក្នុងព្រៃល្បោះដែលស្ថិតនៅចម្ងាយប្រហែល ៣គ.ម ពីផ្ទះ។ ពួកគាត់កាប់រំលំៗទុកចោលក្នុងព្រៃពីរបីថ្ងៃ រហូតបានប្រហែល ១០០ ដើម ទើបជួលគោយន្តគេទៅប្រមូលដឹកយកមកផ្ទះ។ កូនឈើតូចៗដែលគាត់កាប់នោះមានអង្កត់ផ្ចិត៥សង់ទីម៉ែត្រ និងកម្ពស់ ៣ម។ បន្ទាប់ពីដឹកមកដល់ផ្ទះហើយ គាត់បានវាយ ដំបកសំបកកូនឈើទាំងនោះ រួចដាក់ហាលសម្ងួតប្រហែលមួយសប្តាហ៍។ បន្ទាប់មក កាត់កូនឈើទាំងនោះដោយរណាដៃជាកំណាត់ៗប្រវែង ៤០សង់ទីម៉ែត្រ ហើយហាលថែមប្រហែល ៤ ឬ៥ថ្ងៃទៀត រហូតទាល់តែស្ងួតអាចដុតឆេះ ទើបប្រមូលចងជាបាច់ៗ ដោយក្នុងមួយបាច់មានឧសចំនួន ១២ កំណាត់។ គាត់និងកូនត្រូវចំណាយពេលប្រហែល ១៥ថ្ងៃ ដើម្បីផលិតឧសបានចំនួន ២០០បាច់។ បន្ទាប់មក គាត់ត្រូវជួលគោយន្តគេដឹកឧសទាំងអស់ទៅលក់នៅឯផ្សារពង្រ ចម្ងាយប្រមាណ ២០ គ.ម ពីផ្ទះរបស់គាត់។ គាត់លក់ឧសទាំងអស់នោះបានប្រាក់ប្រហែល ២៥ដុល្លារ។ បន្ទាប់ពីកាត់ចំណាយថ្លៃដឹក គាត់ចំណេញបានប្រហែល ១០ ដុល្លារ។ នេះគឺជាប្រភពចំណូលសំខាន់បំផុតសម្រាប់គ្រួសាររបស់គាត់ដែលមានសមាជិកចំនួន ៧នាក់ រួមទាំងម្តាយចាស់របស់គាត់ផង។ ម្តងម្កាល គាត់បានទទួលអំណោយជាអង្ករពីរដ្ឋបាលឃុំ និងវត្តនៅក្បែរផ្ទះ។

អ្នកស្រី បានរៀបរាប់អំពីបញ្ហាប្រឈមក្នុងជីវិត និងបានថ្លែងដោយដកដង្ហើមធំថា «ជីវិតរស់នៅសព្វ ថ្ងៃលំបាកណាស់!។ ខ្ញុំគ្មានដីសម្រាប់រស់នៅ និងធ្វើស្រែចម្ការទេ។ ចំណូលពីការលក់ឧស មិនគ្រប់គ្រាន់សម្រាប់ទ្រទ្រង់ការចំណាយនៅក្នុងគ្រួសារទេ។ អង្ករទម្ងន់ ១០គ.ក ថ្លៃ ៦ ដុល្លារ ហូបបានតែ ៤ថ្ងៃប៉ុណ្ណោះ។»



អ្នកស្រី ស៊ុន កែវ និងកូនៗ នៅមុខផ្ទះខ្ទមរបស់ម្តាយគាត់។

កាលពីខែកក្កដា កន្លងទៅ កូនស្រីតូចៗ ២ នាក់ របស់គាត់ បានធ្លាក់ខ្លួនឈឺធ្ងន់ ត្រូវសម្រាកពេទ្យ។ ដោយត្រូវការប្រាក់បន្ទាន់ គាត់បានបង្ខំចិត្តខ្ចីលុយ ចំនួន ១.០០០ដុល្លារ ពីធនាគារក្នុងស្រុកមួយ ដោយត្រូវបង់សងរំលួសទៅឱ្យធនាគារនោះវិញប្រហែល ៥០ដុល្លារក្នុងខែ។ បច្ចុប្បន្ន គាត់នៅជំពាក់ធនាគារ ចំនួនប្រហែល ៧០០ ដុល្លារទៀត។ អ្នកស្រី កែវ បានថ្លែងដោយទឹកមុខក្រៀមក្រំថា «អត់មានដីនឹងគេ ពិបាកណាស់។ រៀងរាល់យប់ ខ្ញុំមិនដែលបានដេក លក់ស្រួលទេ គិតពីរឿងជីវភាពលំបាក និងអនាគតរបស់កូនៗ។»

អ្នកស្រី កែវ ស្រមៃចង់បានផ្ទះនិងដីស្រែដើម្បីរស់នៅប្រកបរបរចិញ្ចឹមជីវិតឱ្យមានជីវភាពល្អប្រសើរជាងនេះ។ អ្នកស្រី កែវ បានថ្លែងថា៖ «ប្រសិនបើ ខ្ញុំមានដី ខ្ញុំនឹងសង់ផ្ទះមួយ និងដាំបន្លែ ស្រូវ ដើមឈើហូបផ្លែ ចិញ្ចឹមត្រីនិងមាន់។ ដីសំខាន់ណាស់! សំខាន់ដូចជាជីវិតយើងអញ្ចឹង!។»

គម្រោងឡាសិត ៣ នេះ គឺជាក្តីសង្ឃឹមចុងក្រោយរបស់គាត់ដែលអាចជួយឱ្យគាត់ចាកចេញពីភាពក្រីក្របាន។ ផ្អែកលើលក្ខណវិនិច្ឆ័យនៃការជ្រើសរើសមុខសញ្ញាអ្នកទទួលដី គ្រួសារដែលមានស្ថានភាពជីវភាពសមស្របតាមលក្ខណវិនិច្ឆ័យ ជ្រើសរើសជាងគេ នឹងទទួលបានពិន្ទុខ្ពស់ជាងគេ ចំណែកឯ គ្រួសារដែលមានស្ថានភាពជីវភាពគ្រូវ តាមលក្ខណវិនិច្ឆ័យជ្រើសរើសតិចតួចនឹងទទួល បានពិន្ទុទាបជាងគេ។

អ្នកស្រី កែវ ទទួលបានពិន្ទុ២៤ ស្ថិតនៅលេខរៀងទី៣ ក្នុងតារាងពិន្ទុអ្នកស្នើសុំដីសម្បទានសង្គមកិច្ច ដែលមានពិន្ទុខ្ពស់បំផុត ២៦ និងទាបបំផុត ១១។ យោងតាមលក្ខណវិនិច្ឆ័យនៃការជ្រើសរើសដែលក្រុមការងារបច្ចេកទេសចម្រុះនៅឃុំប្រស្នឹប បានអនុម័ត អ្នកដាក់ពាក្យស្នើសុំដីណាដែលមាន ពិន្ទុក្រោម ១៨ នឹងមិនត្រូវបានជ្រើសរើសទេ៕